មេហ្គាលីស៊ីង ភីអិលស៊ី
MEGA LEASING PLC.

# ដំណឹងជ្រើសរើសបុគ្គលិក

មេហ្គាលីស៊ីង ភីអិលស៊ី គឺជាគ្រឹះស្ថានផ្តល់សេវាកម្មភតិសន្យាហិរញ្ញវត្ថុដែលត្រូវ បានបង្កើតឡើងនៅក្នុងឆ្នាំ ២០១៣ និងទទួលបានអាជ្ញាប័ណ្ណជាផ្លូវការ ពីធនាគារជាតិនៃកម្ពុជា នៅក្នុងខែមករា ឆ្នាំ ២០១៤។ បេសកកម្មរបស់គ្រឹះស្ថាន មេហ្គាលីស៊ីង ភីអិលស៊ី គឺផ្តល់សេវាកម្មហិរញ្ញវត្ថុឆាប់រហ័ស ដើម្បីឆ្លើយតបតាមតម្រូវការរបស់អតិថិជន ជាពិសេសទៅលើផលិតផលសម្រាប់ប្រើប្រាស់ និងសម្រាប់អាជីវកម្ម រួមមាន រថយន្តម៉ូតូ, កង់, ឧបករណ៍អេឡិចត្រូនិក គ្រឿងប្រើប្រាស់ក្នុងផ្ទះ គ្រឿងសង្ហារឹម និងឧបករណ៍ និងគ្រឿងចក្របម្រើឲ្យវិស័យកសិកម្ម។ ដើម្បីឆ្លើយតបនឹងការរីកចម្រើនរបស់ខ្លួន ក្រុមហ៊ុនត្រូវការជ្រើសរើសមុខតំណែងដូចព័ត៌មានលំអិតខាងក្រោម៖

**មុខតំណែង:** អ្នកបើកបរ និងជំនួយការរដ្ឋបាលសាខា (០១នាក់)

**ទីតាំងជ្រើសរើស:** សាខាត្បូងឃ្មុំ

**កាលបរិច្ឆេទឈប់ទទួលពាក្យ:** ថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៨

## ភារកិច្ច និងការទទួលខុសត្រូវ៖

- បើកបររថយន្តរបស់មេហ្គាលីស៊ីងដោយស្មារតីប្រុងប្រយត្ន័ និងការទទួលខុសត្រូវខ្ពស់ក្នុងការជូនថ្នាក់ដឹកនាំនិងភ្ញៀវ ព្រមទាំងបុគ្គលិក បំរើការនៅក្នុងការិយាល័យទៅតាមគោលដៅនានាដែលមេហ្គាលីស៊ីងបានកំពុងប្រតិបត្តិការ
- ត្រូវធ្វើឲ្យប្រាកដថារាល់ការបើកបរលើទ្រូងផ្លូវសាធារណៈ ត្រូវអនុវត្តឲ្យបានត្រឹមត្រូវតាមច្បាប់ចរាចរផ្លូវគោកនៃព្រះរាជាណាចក្រ កម្ពុជា
- ត្រូវទទួលខុសត្រូវក្នុងការថែទាំរថយន្ត លាងសំអាត ត្រូវត្រួតពិនិត្យជាប្រចាំនូវប្រេងម៉ាស៊ីនរថយន្ត តំរងប្រេង សំបុកខ្យល់ ជៀសវាងការប្រើហួសការកំណត់ដែលនាំឲ្យយានយន្តឆាប់ខូច និងភ្លើងស៊ីញ៉ូមុខក្រោយ ភ្លើងបំភ្លឺរបស់រថយន្ត ហ្វ្រាំង ស៊ីផ្លេ ត្រូវតែប្រើបានជានិច្ចនៅពេលមានតំរូវការប្រើប្រាស់។
- ត្រូវរាយការណ៍ជូនប្រធានគ្រប់គ្រងជាបន្ទាន់ក្នុងករណីដែលរថយន្តមានការខូចខាត ឬក៏មានគ្រោះថ្នាក់ផ្សេងៗ។
- ត្រូវសហការណ៍ជាមួយសន្តិសុខការិយាល័យក្នុងការចាក់ប្រេងម៉ូតូសំរាប់ម៉ូតូមេហ្គាលីស៊ីងទាំងអស់ និងត្រូវជួយពិនិត្យមើលគ្រឿង សំខាន់ៗដូចជា ហ្វ្រាំង ម៉ូតូ ស្ថានភាពម៉ាស៊ីន សំបកកង់ និងលក្ខណៈមួយចំនួនទៀតដែលចាំបាច់សំរាប់ការធ្វើដំណើរបំពេញ ការងាររបស់បុគ្គលិក។
- ធ្វើកិច្ចការការិយាល័យមួយចំនួនដូចជាការថតចំលងឯកសារ ការទិញសំភារៈផ្សេងៗ ការផ្ញើ និងទទួលឯកសារ ដែលផ្ញើឲ្យសាខានិងផ្ញើពីសាខាទៅតាមគោលដៅនានា។
- បំពេញកិច្ចការងារផ្សេងៗទៀតតាមការចាត់តាំងរបស់ប្រធានគ្រប់គ្រងផ្ទាល់និងថ្នាក់មានសមត្ថកិច្ចក្នុងក្របខណ្ឌភារៈកិច្ចការងាររបស់មេហ្គាលីស៊ីង។

## លក្ខខណ្ឌជ្រើសរើស៖

1. ត្រូវមានសញ្ញាប័ត្រប្រឡងជាប់មធ្យមសិក្សាទុតិយភូមិ
2. ត្រូវគាំទ្រដោយឥតងាករេនូវទស្សនៈវិស័យ និងបេសកកម្មរបស់មេហ្គាលីស៊ីង
3. ស្មោះត្រង់ មានប្រវត្តិរូបល្អ អាកប្បកិរិយាល្អ រួសរាយរាក់ទាក់តែហ្មត់ចត់ និងប្រាកដប្រជាជាមួយការងារ
4. មានជំនាញក្នុងការបើកបរដោយប្រើប្រាស់លេខដៃ លេខអូតូ និងមានប័ណ្ណបើកបរប្រភេទទេសចរណ៍ ដែលមានសុពលភាពចេញដោយក្រសួងសាធាណៈការ មានចំណេះដឹងច្បាស់លាស់ពីច្បាប់ចរាចរ និងផ្លាកសញ្ញាចរាចរ
5. មានសមត្ថភាពក្នុងការជួសជុលរថយន្ត និងការថែរទាំរថយន្ត រិតតែប្រសើរ
6. ធ្លាប់មានបទពិសោធន៍ក្នុងមុខតំណែងយ៉ាងហោចណាស់០១ឆ្នាំ ជាមួយក្រុមហ៊ុន ឬអង្គការ។
7. មានចិត្តអត់ធ្មត់ នឹងស្រលាញ់ការងារដែលគ្រឹះស្ថាន ប្រគល់ជូន
8. ជាញឹកញាប់អាចចុះតាមបណ្តាខេត្តផ្សេងៗដែលជាតំបន់ប្រតិបត្តិការរបស់មេហ្គាលីស៊ីង

ក្រុមហ៊ុន មេហ្គាលីស៊ីង ភីអិលស៊ី និងធ្វើការផ្តល់ប្រាក់បៀវត្សក្នុងលក្ខណៈប្រកួតប្រជែង និង មានកំណើនទៀងទាត់ប្រចាំឆ្នាំ។ មានផ្តល់ប្រាក់ឧបត្ថម្ភ ចូលឆ្នាំខ្មែរ និង បុណ្យភ្ជុំបិណ្ឌ, ប្រាក់លើកទឹកចិត្ត, ប្រាក់សោធននិវត្តន៍ ការធានារ៉ាប់រងសុខភាព និង គ្រោះថ្នាក់ 24 ម៉ោង , ធានារ៉ាប់រងអាយុជីវិត និង មានការឈប់សម្រាកស្របទៅតាមច្បាប់ការងាររួមទាំងអត្ថប្រយោជន៍ផ្សេងៗជាច្រើនទៀត។

ប្រសិនបើបេក្ខជននិងបេក្ខនារីមានចំណាប់អារម្មណ៍ អាចផ្ញើប្រវត្តិរូបសង្ខេប និងលិខិតអម (CV and Cover letter) ព្រមទាំងថតចម្លងឯកសារដូចខាងក្រោម៖

- សញ្ញាបត្រដែលទទួលបាន ឬ លិខិតបញ្ជាក់ការសិក្សាពីសាកលវិទ្យាល័យ
- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬ ឯកសារដែលមានតំលៃស្មើ
- សៀវភៅគ្រួសារ និង សំបុត្របញ្ជាក់កំណើត

សូមផ្ញើមកកាន់នាយកដ្ឋានធនធានមនុស្ស មេហ្គាលីស៊ីង ភីអិលស៊ីតាមរយៈ អាស័យដ្ឋាន ផ្ទះលេខ៦៧ ផ្លូវលេខ១២៥ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ ឬផ្ញើមកតាមរយៈ អ៊ីមែល៖ recruitment@megaleasing.com.kh ឬ ព័ត៌មានបន្ថែមអាចទាក់ទងតាមរយៈទូរសព្ទ៖ ០៦៩ ៥២២ ៥២២/០៦៩ ៣៦៤ ៦៦៦

ធ្វើឲ្យជីវិតទាន់សម័យ